# សេចក្តីណែនាំសម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងពេលសវនាការសាធារណៈ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានគោលបំណងផ្តល់ព័ត៌មាននានាទាក់ទងអំពីសកម្មភាពរបស់ខ្លួនជូនដល់តំណាងប្រព័ន្ធផ្សព្វផ្សាយទាំងថ្នាក់ជាតិនិងអន្តរជាតិ។ ផ្នែកកិច្ចការសាធារណៈគឺមុខមាត់របស់អ.វ.ត.ក ហើយនិងធ្វើការគាំទ្រក៏ដូចជាសម្របសម្រួលដល់សាធារណជននិងប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការពាក់ព័ន្ធជាមួយនឹងអ.វ.ត.ក។

## ការចុះឈ្មោះសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ

តំណាងប្រព័ន្ធផ្សព្វផ្សាយដែលយកព័ត៌មានអំពីកិច្ចការរបស់អ.វ.ត.ក គឺតម្រូវឲ្យមានការចុះឈ្មោះជាមួយនឹងអ.វ.ត.ក។ ដើម្បីទទួលបាននូវការទទួលស្គាល់ អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវបំពេញទម្រង់បែបបទពាក្យសុំចុះឈ្មោះដោយភ្ជាប់មកជាមួយនូវរូបថតផងដែរ។ បុគ្គលិកផ្នែកកិច្ចការសាធារណៈ នឹងជួយទៅដល់អ្នកដែលមានប័ណ្ណ និងសម្របសម្រួលដល់ពួកគេនៅពេលដែលពួកគេត្រូវការជំនួយ។

ពាក្យសុំចុះឈ្មោះសម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់អ.វ.ត.ក http://www.eccc.gov.kh/english/mediaRelations.aspx ឬក៏អាចយកបាននៅការិយាល័យផ្នែកកិច្ចការសាធារណៈនៅអ.វ.ត.ក។ សូមមេត្តាផ្ញើពាក្យសុំដែលមានចុះហត្ថលេខាព្រមជាមួយនឹងរូបថតមកកាន់លោកម៉ៅ វុត្ថា តាមរយៈ mao.vutha@eccc.gov.kh ។

## បន្ទប់ព័ត៌មាន (C105)

បន្ទប់ព័ត៌មាន(C105 និង C109) ត្រូវបានបំរុងទុកសម្រាប់តំណាងអ្នកសារព័ត៌មានដែលបានចុះឈ្មោះរួច ដែលក្នុងនោះកន្លែងអង្គុយចំនួន៥០ សម្រាប់បន្ទប់ C105 និង៣០ កន្លែងទៀតសម្រាប់បន្ទប់ C109។

នៅពេលទទួលបានការអនុញ្ញាតពីសំណាក់ចៅក្រម ប្រព័ន្ធសោតទស្សន៍ (រូបភាពនិងសំឡេង)នៃដំណើរការសវនាការជាភាសាខ្មែរ អង់គ្លេស និងបារាំង នឹងត្រូវតភ្ជាប់មកកាន់បន្ទប់ C105។ (សូមមើលបន្ថែមក្នុង **លទ្ធភាពខាងផ្នែកសោតទស្សន៍**)

**កន្លែងអង្គុយនៅក្នុងសាលសវនាការ**

ផ្នែកកិច្ចការសាធារណៈបានរៀបចំបំរុងទុកកន្លែងអង្គុយចំនួន៣០ សម្រាប់តំណាងប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសាលសវនាការ បន្ថែមលើចំនួនកន្លែងអង្គុយដែលមាននៅក្នុងបន្ទប់ព័ត៌មាន(C105) និងC109) អ្នកទាំងឡាយណាដែលមានបំណងចូលរួមក្នុងសាលសវនាការគឺតម្រូវឲ្យចុះឈ្មោះជាមុន ហើយត្រូវមានវត្តមានយ៉ាងហោចណាស់ ៣០ នាទីមុនពេលដំណើរការសវនាការចាប់ផ្តើម។ អ្នកដែលចូលក្នុងសាលសវនាការតម្រូវឲ្យយកចូលតែសម្ភារៈសម្រាប់កត់ត្រាតែប៉ុណ្ណោះ ដោយឡែក សម្រាប់ឧបករណ៍អេឡិចត្រូនិចផ្សេងៗដែលអាចប្រើប្រាស់សម្រាប់ថតសម្លេង ឬរូបភាព (ទូរស័ព្ទ ឧបករណ៍ថត និងកុំព្យូទ័រយួរដៃ) នឹងមិនត្រូវអនុញ្ញាតឲ្យយកចូលក្នុងសាលសវនាការជាដាច់ ខាត។ ទូរសុវត្ថិភាពសម្រាប់ដាក់ឧបករណ៍ទាំងអស់នោះ គឺមាននៅក្នុងបន្ទប់ (C108) ដែលស្ថិត នៅខាងក្រៅសាលសវនាការ។ អ្នកចូលរួមក្នុងសាលសវនាការទាំងអស់ត្រូវរក្សានូវភាពថ្លៃថ្នូ និង ស្លៀកពាក់ឲ្យបានសមរម្យ ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងសម្រាប់សវនាការ។

**ឱកាសសម្រាប់ថតរូប**

ចៅក្រមអង្គជំនុំជម្រះបានអនុញ្ញាតបើកឱកាសឲ្យមានការថតរូបអំពីដំណើរការសវនាការ (ប្រហែល៥នាទី)។ ក្រុមតំណាងអ្នកសារព័ត៌មានដែលមានចំនួនកំណត់មួយនឹងត្រូវជ្រើសរើសចូលទៅថតរូបក្នុង សាលសវនាការ។ ក្រុមតំណាងនោះមានចំនួន៦នាក់ ដែល៣នាក់សម្រាប់ថតរូបសន្លឹក និង៣នាក់ផ្សេងទៀតថតវីដេអូ។ សម្រាប់សមាសភាពក្រុមតំណាងថតរូបសន្លឹករួមមានអ្នកថតរូបមួយនាក់តំណាងឲ្យសារព័ត៌មានក្នុងស្រុក អ្នកថតរូបមួយនាក់តំណាងឲ្យសារព័ត៌មានអន្តរជាតិ និងអ្នកថតរូបម្នាក់ផ្សេងទៀតតំណាងឲ្យទីភ្នាក់ងារសារព័ត៌មាន។ ចំណែកឯសមាសភាពក្រុមតំណាងអ្នកថតវីដេអូរួមមាន ការីថតម្នាក់តំណាងឲ្យស្ថានីយទូរទស្សន៍ក្នុងស្រុក ការីថតអន្តរជាតិម្នាក់ដែលប្រើប្រាស់ស្តង់ដារ PAL និងការីថតអន្តរជាតិម្នាក់ទៀតដែលប្រើប្រាស់ស្តង់ដារ NTSC។ តំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានបំណងចូលរួមក្នុងឱកាសសម្រាប់ថតរូប ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១. ប័ណ្ណសំគាល់អ្នកសារព័ត៌មានមានប្រសិទ្ធិភាពដែលចេញដោយអ.វ.ត.ក

២. អ្នកថតនិងការីថតមានលក្ខណៈសម្បត្តិនិងប្រកបដោយឧបករណ៍វិជ្ជាជីវៈគ្រប់គ្រាន់

៣. ការចូលរួមក្នុងការថតរូបនេះគឺត្រូវធ្វើឡើងតាមលក្ខណៈវិលជុំ

### លទ្ធភាពខាងផ្នែកសោតទស្សន៍

នៅពេលទទួលបានការអនុញ្ញាតពីសំណាក់ចៅក្រម ប្រព័ន្ធសោតទស្សន៍ស្តីពីដំណើរការសវនាការនឹងត្រូវផ្សាយបន្តផ្ទាល់ដល់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់។ ការផ្សាយបន្តផ្ទាល់នេះគឺមិនតម្រូវឲ្យបង់ថ្លៃនោះទេ។ បណ្តាញសម្រាប់ភ្ជាប់កសំឡេងគឺប្រើប្រព័ន្ធ XRL រីឯបណ្តាញសម្រាប់ភ្ជាប់វីដេអូវិញគឺប្រើប្រព័ន្ធ BNC។ ឧបករណ៍តភ្ជាប់សម្រាប់វីដេអូចំនួន២០ និងឧបករណ៍តភ្ជាប់សំឡេងចំនួន១៦ ក្នុងមួយភាសាណឹងត្រូវផ្តល់ជូននៅក្នុងបន្ទប់(C105) ។

### លទ្ធភាពខាងផ្នែកអ៊ីនធើណិត

បន្ទប់អ៊ីនធើណិត (C108) គឺជាកន្លែងដ៏ស្ងប់ស្ងាត់សម្រាប់ធ្វើការងារ ដែលនៅក្នុងនោះមានបំពាក់ទៅដោយកុំព្យូទ័រមានភ្ជាប់ប្រព័ន្ធអ៊ីនធើណិតរួចជាស្រេច។ ការប្រើប្រាស់អ៊ីនធើណិតគឺធ្វើឡើងតាមរបូបមន្តអ្នកដែលមកមុនប្រើមុន។ កុំព្យូទ័រប្រភេទយួរដៃនឹងមិនអនុញ្ញាតឲ្យតភ្ជាប់ទៅនឹងប្រព័ន្ធអ៊ីនធើណិត និងបណ្តាញរបស់ អ.វ.ត.ក នោះទេ ហើយក៏គ្មានការផ្តល់ឲ្យនូវប្រព័ន្ធតភ្ជាប់អ៊ីនធើណិតគ្មានខ្សែនោះដែរ។ នៅក្នុងបន្ទប់នេះក៏មានទូរសម្រាប់ដាក់សម្ភារៈនានាដូចជាម៉ាស៊ីនថតរបស់អ្នកសារព័ត៌មានរូបណាដែលមានបំណងចូលទៅទស្សនាផ្ទាល់ក្នុងសាលសវនាការ។

### ទីតាំងសម្រាប់ឈរវាយការណ៍ព័ត៌មាន

មានទីតាំងចំនួន២កន្លែងបានបំរុងទុកនៅខាងក្រៅអាគារសវនាការសម្រាប់អ្នកសារព័ត៌មានទូរទស្សន៍ឈរធ្វើសេចក្តីវាយការណ៍ព័ត៌មាន។ ទីតាំងទីមួយគឺនៅខាងមុខសាលសវនាការដោយមើលឃើញអាគារសវនាការនិងទង់ជាតិ។ ទីតាំងមួយកន្លែងទៀតគឺនៅជិតរោងលោកតាដំបងដែក។ គ្មានការអនុញ្ញាតសម្រាប់ទីតាំងដ៏ទៃទៀតនោះទេ។

### សន្និសីទសារព័ត៌មាន

សន្និសីទសារព័ត៌មាននឹងត្រូវធ្វើឡើងទៅតាមតម្រូវការនៅក្នុងបន្ទប់ព័ត៌មានដែលរៀបចំដោយផ្នែកកិច្ចការសាធារណៈ។ ការបកប្រែទាំង៣ភាសាផ្លូវការនឹងផ្តល់ជូនក្នុងពេល សន្និសីទសារព័ត៌មាន។ មានតែតំណាងអ្នកសារព័ត៌មានប្រព័ន្ធផ្សព្វផ្សាយដែលទទួលស្គាល់ដោយអ.វ.ត.ក ប៉ុណ្ណោះនឹងត្រូវអនុញ្ញាតឲ្យចូលរួមក្នុងសន្និសីទសារព័ត៌មាននេះ។

*តំណាងអ្នកសារព័ត៌មានប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវចងចាំថាការទាក់ទងដោយផ្ទាល់ជាមួយនឹងចៅក្រម មន្ត្រីច្បាប់ និងភាគីផ្សេងៗ គឺជាការមិនសមរម្យ។ រាល់សំណួរនិងសំណូមពរសម្រាប់ព័ត៌មានទាំងអស់ត្រូវធ្វើឡើងធ្វើឡើងដោយផ្ទាល់ទៅកាន់ផ្នែកកិច្ចការសាធារណៈ។*

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**

- បណ្ឌិត ហេឡិន ចារវីស ទូរស័ព្ទលេខ 012 488 134
- លោក រាជ សម្បត្តិ ទូរស័ព្ទលេខ 012 488 156
- លោក ម៉ៅ វុត្ថា ទូរស័ព្ទលេខ 092 828 283 / 011 364 444